# ការសម្ភាសរបស់ ខឹមស្រី

ក. អ្នកសម្ភាស គង់ សីហា ខ. ខឹមស្រី

ក. បាទសូមជម្រាបសួរបងសម្រាប់ខ្ញុំ ខ្ញុំឈ្មោះគង់សីហា ជាអ្នកសម្ភាសថ្ងៃហ្នឹង ហើយយើងធ្វើឡើងនៅកន្លែងធ្វើការរបស់បងអង្គការCJFណាបង?

ខ. ចាស៎!

ក. បាទហើយអញ្ចឹងខ្ញុំសូមសួរសំនួរបងឈ្មោះអីដែរ? ឈ្មោះពេញ?

ខ. ឈ្មោះខឹមស្រី

ក. ខឹមស្រីបងណ៎ា? ហើយក្នុងការសម្ភាសហ្នឹងយើងធ្វើឡើងដោយសកលវិទ្យាល័យមួយដែលនៅសហរដ្ឋអាមេរិច គឺគេមានគម្រោងហ្នឹងធ្វើដើម្បីសម្ភាសដល់សមាជិក និង ក្រុមគ្រួសារនៅប្រជាជននៅស្រុកខ្មែរដើម្បីទុកនៅក្នុងវេបសាយមួយ នឹងនៅថ្ងៃអនាគតទៅគឺ ជាពរជ័យមួយសម្រាប់កូនចៅយើងទាំងអស់គ្នា ដើម្បីកាលណាគាត់ចប់ដឹងថាតើជីវប្រវត្តិឪពុកម្ដាយ គាត់យ៉ាងម៉េចឆ្លងកាត់អីខ្លះគាត់អាចចូលតាមវេបសាយរបស់យើងសាលារៀនយើងទៅ គឺគាត់អាចស្ដាប់បានអី អញ្ចឹងណាបង?

ខ. ចាស៎!

ក. អញ្ចឹងនៅពេលដែលខ្ញុំសម្ភាបងឱ្យរួចរាល់ហើយសម្លេងបង រូបភាពបង រូបថតបង ខ្ញុំអាចសូមដាក់ចូលវេបសាយ ពួកយើងបានទេ?

ខ. (សើច) បានតើ!

ក. អញ្ចឹងបង ខ្ញុំចង់សួមសួរសំនួរមួយ បងមានឈ្មោះ ឈ្មោះហើយក្រៅកាលពីនៅក្មេង ឫក៏ឈ្មោះនៅផ្ទះអីអញ្ចឹង?

ខ. កាលនៅពីក្មេង ម៉ាក់បងគាត់ដាក់ឈ្មោះបង សុកហួន ដល់ពេលក្រោយមកហ្នឹងគាត់ដូរដាក់ខឹមស្រី វិញទៅ ហើយហៅឈ្មោះស្រីស្រីរហូត។

ក. បាទបងហើយមានឈ្មោះអីទៀតទេ?

ខ. អត់មានឈ្មោះអីទៀតទេ ។

ក. អញ្ចឹងហ្ន៎បង?

ខ.ចាស៎!

ក. បាទ! ហើយសម្រាប់បង បងឥឡូវហ្នឹងមានអាយុប៉ុន្មានហើយ?

ខ. ឥឡូវហ្នឹងមានអាយុ៥៦ហើយ ។

ក. បងកើតនៅថ្ងៃខែឆ្នាំណាដែរ?

ខ. កើតនៅឆ្នាំ១៩៧០ ។

ក. តើបងចាំថ្ងៃទេ? ចាំខែទេ?

ខ. អត់ចាំ ។ ថ្ងៃខែអត់ចាំ ។

ក. អញ្ចឹងបងចាំទីកន្លែងកំណើតទេ?

ខ. ទីកន្លែងកំណើតហ្នឹងក៏នៅខេត្តកំពង់ធំស្រុកបារាយណ៍ ឃុំសាយ៉ូង។

ក. បាទបងហ្នឹងហើយ អញ្ចឹងភាគច្រើនស្រុកខ្មែរយើងច្រើនតែប្រើឆ្នាំសត្វអី អញ្ចឹងសម្រាប់បងសត្វអីគេដែរ ?

ខ. សត្វជ្រូក ។

ក. បាទអញ្ចឹង ខ្ញុំចង់សូមសួរសំណួរខ្លះៗថាតើបងដែលរៀនភាសាផ្សេងក្រៅពីភាសាខ្មែរទេ ?

ខ. អត់ដែរ ចង់ប៉ុន្តែអត់មានពេលវេលារៀន។

ក. ហើយបងរៀនភាសាខ្មែរទេ?

ខ. បងរៀនភាសាខ្មែរ ។

ក. ហើយបងរៀនដល់ថ្នាក់ទីប៉ុន្មានហើយបង?

ខ. បងរៀនចប់ឆ្នាំ...បងរៀនបានត្រឹមថ្នាក់ទីប្រាំ ។

ក. ថ្នាក់ទីប្រាំ សម័យឥឡូវថ្នាក់ទីប៉ុន្មានដែរបង?

ខ. ទីប្រាំប្រហែលជា ២៥ឆ្នាំមុន ។

ក. បាទហើយអញ្ចឹងចង់សូមសួរបន្ថែមទៀតអំពីរឿងការរៀបអាពាហ៍ពិពាហ៍បងវិញ ។

ខ. (គាត់សើច)

ក. ហ្នឹងហើយរឿងស្នេហា អញ្ចឹងបង អញ្ចឹងបង បានថាយើងម្នាក់ៗអ្នកណាក៏ដូចអ្នកណាដែរគឺ យើងឆ្លងកាត់នូវការរៀបអាពាហ៍ពិពាហ៍ ។ សម្រាប់បង បងដែលរៀបការទេបង?

ខ. ដែល ។

ក. បងរៀបការប៉ុន្មានដងដែរ ?

ខ. ម្ដង!

ក. ម្ដងបង ?

ខ. ហ្នឹងហើយ! ម្ដង!

ក. បងចាំហើយថា បងរៀបការហ្នឹងនៅឆ្នាំណាដែរបង ?

ខ. ២០០៩

ក. ហើយបងការនៅណាវិញ ?

ខ. ការនៅខេត្តកំពង់ធំ ។

ក. ខេត្តកំពង់ធំ?

ខ. ចា៎ ស្រុកបារាយ ។

ក. អញ្ចឹងការរៀបអាពាហ៍ពិពាហ៍បងគឺឪពុកម្ដាយទុកដាក់ជូនបងឬបងដោយខ្លួនឯង ?

ខ. យើងធ្វើការជាមួយគ្នាទៅមើលឃើញគ្នាទៅក៏ម្ដាយឪពុកគេខាងគេស្ដីស្តួរយើងរៀបការ ។

ក. អញ្ចឹង ដោយសារតែបងស្រឡាញ់គ្នាទៅវិញទៅមកដែរមែនទេបង ?

ខ. ចាស៎!

ក. ហើយនៅពេលដែលបងរៀបការហ្នឹងបងបាន មានបានបណ្ដាការអីទេ?

ខ. បណ្ដាការគេបង្គាប់ហ្នឹងមែន**?**

ក. ហ្នឹងហើយៗ!

ខ. កាលហ្នឹងគាត់បង់យកថ្លៃផ្ទះបាន៦០០ ។

ក. បាទបង! ហើយនៅពេលដែលបងបានលុយហ្នឹងទៅបងយកទៅធ្វើអ្វីគេ?

ខ. បងយកចាត់ចែងទិញ ទិញដូចថាយើងយកទៅកក់ថ្លៃតុថ្លៃភ្លេង ថ្លៃអាចារ្យថ្លៃអីគេអញ្ចឹងទៅ។

ក. ខ្ញុំចង់ដឹងអំពីរៀបការ រៀបអាពាហ៍ពិពាហ៍ម្តងទៀតកាលជួបគ្នាម្តង ។ អញ្ចឹងមានន័យថាពេលដែលបងជួបហ្នឹង ធ្វើអ្វីឱ្យបងជួបគ្នា ហេតុអី បានមានសាងភាពស្នេហារហូតដល់ការរៀបការអញ្ចឹង សូមបងអាចជួយរាបរាប់ពីដើមដំបូងមកដល់បានរៀបការ ។

ខ. កាលហ្នឹងយើងធ្វើការជាមួយគ្នា ដល់ពេលធ្វើការជាមួយគ្នាយើងទៅមើលចិត្តគ្នាទៅវិញទៅមកយើងយល់ចិត្តគ្នាទៅ ក៏យើងខាងប្រុសនិងគេឱ្យម៉ែឪគេមកស្តីដណ្តឹងយើងតាមប្រពៃណីយើងទៅ ហើយយើងបានរៀបចំអាពាហ៍ពិពាហ៍អញ្ចឹងទៅ ។

ក. ហើយបងប្រុសជួបបងម៉េចដែរបានគាត់មានចាប់ចិត្តថាគាត់នឹងនាំឪពុកម្តាយគាត់ភ្ជាប់ពាក្យបង ?

ខ. មានតែប៉ុណ្ណឹង ធ្វើការជាមួយគ្នានឹកឃើញគ្នា ។

ក. បើដោយសារយើងអ្នកខ្លះគាត់ឃើញបើដោយសារបងស្រីហ្នឹង វាចំណុចមួយដែលពិសេសកន្លែងនេះ បានគាត់ចាប់អារម្មណ៍ ហើយបងស្រីឃើញគាត់មានចំណុច កន្លែងនេះបានគាត់ចាប់អារម្មណ៍អញ្ចឹង? អញ្ចឹងតើបងមានអីហ្នឹងទេ?

ខ. គ្រាន់តែឮថាគាត់ និយាយទៅស្វាមីបង គាត់អាយុក្មេងជាងបង ដល់អញ្ចឹង ពេលសួរបងអញ្ចឹងបងគិតថាបងអត់យកទេប្តីក្មេង គាត់ថា គាត់ចង់បានចាស់ ភរិយាចាស់ គាត់អត់ចង់បានក្មេងទេ ។ ហ្នឹងហើយ ហើយបង បងប្រកែក បងថា អត់យកទេ ។ ប្តីក្មេងអញ្ចឹង ហ្នឹងហើយគាត់គិតថា ហើយបងថា បងក្រ គាត់ថា គាត់អត់ចង់បានមានទេ ព្រោះគាត់ក្រដែរ គាត់ចង់បានក្រដូចគ្នា ។

ក. បាទ! តែប៉ុណ្ណឹងបង?

ខ. ចាស់!

ក. ហ្នឹង នៅពេលដែលបងបានការជាមួយនឹងគ្នាហើយ បងនៅកំពង់ធំហ្នឹង ឬក៏ដែរបងបានមកនៅភ្នំពេញ?

ខ. ពេលបងរៀបអាពាហ៍ពិពាហ៍ហើយបងមកនៅភ្នំពេញ មកនៅធ្វើការរហូតដល់សព្វថ្ងៃនេះ ។

ក. ហើយបងមានបងប្អូនប៉ុន្មាននាក់បង?

ខ. បងមានបង់ប្អូនប្រាំបួននាក់ ។

ក. បងអាចជួយរៀបរាប់ឈ្មោះពួកគាត់ហើយអាយុពួកគាត់បានទេ?

ខ. ឈ្មោះបងទីមួយឈ្មោះ ខឹមប៉េងអាន ។ បងទីពីរឈ្មោះ ខឹមលឹមហោង ស្រី ។ បងទីបី ខឹមប៉េងឈាង ។ បងទីបួនឹមប៉េងឈុន ។ ដល់ពេលមកបងទីប្រាំ ខឹមណឹមយ៉េង ។ ទីប្រាំមួយឈ្មោះ ខឹមសុកហៀង ។ ទីប្រាំពីរឈ្មោះ ខឹមប៉េងហួរ ។ ដល់...ទីប្រាំបី (គាត់សើច ហើយមិនចាំ) ។

ក. ដល់ទីប្រាំបួន ?

ខ. ទីប្រាំបួន បង--ទីប្រាំបួនខឹមស្រី ។

ក. អញ្ចឹងសម្រាប់បង បងជាកូនទីប៉ុន្មានដែរ?

ខ. បងកូនទីប្រាំបួន កូន៣៧ ។

ក. ហើយអញ្ចឹងសម្រាប់ពួកបងៗ របស់បងគាត់នៅណាវិញរាល់ថ្ងៃ?

ខ. រាល់ថ្ងៃគាត់នៅបាត់ដំបង ពីរនាក់ប្រុសទាំងពីរ ហើយស្រីមួយប្រុសមួយស្លាប់ ហើយនៅកំពង់ធំហ្នឹងបីនាក់ បងនៅភ្នំពេញ នៅភ្នំពេញ គ្រាន់ជានៅរកស៊ីអញ្ចឹង នៅធ្វើការរកស៊ី ។

ក. អញ្ចឹងបងមកអញ្ជើញមកនៅភ្នំពេញនិងគឺដោយសារតែបងមកនៅរកស៊ីតែប៉ុណ្ណឹង។

ខ. ចំា រកស៊ីធ្វើការនៅនឹង ។ ប៉ុន្តែផ្ទះសម្បែងអីយើងនៅកំពង់ធំអញ្ចឹង ។

ក. បាទបងហ្នឹងហើយ! ហើយសម្រាប់បងមកនៅភ្នំពេញហ្នឹងប៉ុន្មានឆ្នាំហើយបង?

ខ. បងមកនៅភ្នំពេញនិងបងចេញមកតាំងពី ២០០១ ។

ក. បាទ ច្រើនឆ្នាំហើយ អញ្ចឹងជាងដប់ឆ្នាំជាងហើយ ។ ហើយពេលបងមកនៅមុនដំបូងហ្នឹង បងនៅម្តុំណាវិញបង?

ខ. បងមកនៅភ្នំពេញមុនដំបូង បងមក បងពីការប៉ូរីយ៉ូរអញ្ចឹងបងមកធ្វើអនប មកធ្វើអនប់ អញ្ចឹងគេធ្វើជើងឱ្យបងពាក់ជើងហ្នឹង តម្លៃ450គេឱ្យបងពាក់អញ្ចឹង ទៅប៉ុន្តែបងនៅពេលពាក់ទៅយើងពិបាកដើរពិបាកអី។ ពេលពិបាកដើរពិបាកពាក់ដើរក៏ពិបាក ពេលអង្គុយក៏ពិបាកអញ្ចឹងទៅ បងឈប់ពាក់ ដល់ពេលបងឈប់ពាក់ទៅបងដើរអត់ពាក់អនបអត់ពាក់អនបធម្មតាអញ្ចឹងទៅ ។ ដល់ហើយក៏NCDP អង្គការNCDP ខាងជនពិការហ្នឹងគាត់នាំបងរកការងារធ្វើ បងធ្លាប់ធ្វើការងាររោងចក្រ ធ្លាប់ធ្វើការរោកចក្របានក្នុងមួយឆ្នាំហ្នឹង ពីររោងចក្រ ដល់ពេលចេញពីហ្នឹងមកបងធ្វើធូបក្រអូប ធ្វើទុកកាអូបនៅផ្សារមាន់អាំង ធ្វើធូបក្រអូបនៅផ្សារមាន់អាំង ហើយអញ្ចឹងទៅក៏ឈប់ថៅកែ

ឥឡូវ ហ្នឹងគាត់ឈប់ទៅក៏បងនឹងចូលធ្វើការខាងដេរកាបូប នៅទួលទំពូង ជាមួយអ្នកគ្រូយៀក ហុង ធ្វើការជាមួយអ្នកគ្រូយៀក ហុងតាំងពី២០០១ ធ្វើបាន៩ឆ្នាំជិតដប់ឆ្នាំដែរបានឈប់ ។

ក. យូរហើយបង?

ខ. ហ្នឹងហើយ ដល់ពេលឈប់ទៅបងទៅធ្វើការនៅកន្លែងផ្សេងទៀតនៅបឹងកេងកង ដេរកាបូបដែរ។ បងឈប់ធ្វើការពីបឹងកេងកងទៅ ទៅធ្វើនៅទួលមុខផ្ទះ (គាត់ឈប់មួយឬពីរវិនាទី) ជិតវិមានឯករាជ្យ បងធ្វើនៅហ្នឹងបានជិតដប់ឆ្នាំទៀត ប្រាំបីប្រាំបួនឆ្នាំទៀត ។
ហើយឈប់ពីនឹងទៅបានមកធ្វើការនៅ CJF ចុងក្រោយ ។

ក. បាទបង ហ្នឹងហើយ! ហើយអញ្ចឹងមានន័យថាបងបែកពីក្រុមគ្រួសាមកតាំងពីយូរប៉ុន្មានឆ្នាំហើយបង ?

ខ. បងបែកមកតាំងពីអាយុ ៣៩ ឆ្នាំ -- ៣៨ ៣៩ ឆ្នាំ ។

ក. ហើយបងចាំអំពីក្រុមគ្រួសាបងទេ ? ឪពុកម្ដាយបងបានន័យថាគាត់ហ្នឹង គាត់ឈ្មោះអីដែរ ហើយគាត់មានអាយុប៉ុន្មានដែរ ?

ខ. ប៉ាខ្ញុំហ្នឹង គាត់...ខ្ញុំកើតមកអត់ទាន់ទេ ខ្ញុំកើតមកបានតែពីរខែ ចូលជំនាន់ប៉ុលពត ហើយគេយកគាត់ទៅសម្លាប់ចោល បងអត់ដែលស្គាល់មុខគាត់ថាយ៉ាងមេចទេ ។

ក. តើបងស្គាល់ឈ្មោះគាត់ទេ ?

ខ. ស្គាល់ឈ្មោះ ។ ឈ្មោះគាត់ហ្នឹងឈ្មោះ ដេញ អឹងហ៊ី ។

ក. ហើយគិតថាគាត់មានអាយុប៉ុន្មានឆ្នាំ ?

ខ. កាលពីគាត់ស្លាប់ហ្នឹងឯគាត់អាយុ ៤៨ជំនាន់ប៉ុលពត ។ ឥឡូវ ៨០ជាងហើយ ចូល ៨៩ ហើយ ។

ក. ហើយចុះសម្រាប់ម្ដាយបងវិញ ?

ខ. ម្ដាយខ្ញុំហ្នឹងគាត់ស្លាប់បានពីរឆ្នាំហើយ កាលពីគាត់ស្លាប់អាយុ ៨៧។ គាត់ឈ្មោះ ខឹម លឹមអេង។

ក. ហើយគាត់កើតនៅណាវិញបង ? ឪពុកម្ដាយបង ?

ខ. ឪពុកបងកើតនៅ កំពង់ធំ ស្រុកបារាយណ៍ ហើយម្ដាយខ្ញុំកើតនៅខេត្តកំពង់ចាម គេហៅភូមិអំពិលទ្វារ ។

ក. ហើយចុះសម្រាប់ជីដូនជីតាបង បងចាំអ្វីពីពួកគាត់ខ្លះទេ ? គាត់ឈ្មោះអីគេដែរ ?

ខ. ជីដូនជីតាខ្ញុំ គាត់និយាយទៅ កុង (តា) ខ្ញុំមកពីស្រុកចិន មកទៅបានឃើញម៉ា(យាយ) ខ្ញុំនៅស្រុកខ្មែរហ្នឹងទៅក៏បានរៀបចំគ្នា ហើយនិយាយទៅខ្ញុំអត់ទាន់គាត់ទេ គាត់បានចែកឋានយូរហើយ ។

ក. តើបងចាំឈ្មោះគាត់ទេ ?

ខ. អត់ចាំនាមត្រកូលទេចាំតែឈ្មោះៗគាត់ ។

ក. ឈ្មោះអីគេបង ?

ខ. ឈ្មោះខាងប៉ាខ្ញុំឈ្មោះ កុងចើ ម៉ានាង តែឈ្មោះខាងម្ដាយខ្ញុំ កុង ខឹម ម៉ា លុន ។

ក. អញ្ចឹងជីដូនជីតាបងជូនជាតិចិន ។

ខ. ចិន គាត់មកពីស្រុកចិន ប៉ុន្តែម្ដាយខ្មែរ ឪពុកចិនឆៅ ។ គាត់និយាយខ្មែរអត់ច្បាស់ទេ ។

ក. សម្រាប់ម្ដាយឪពុកបងវិញ ដែលទៅប្រទេសក្រៅទេ ?

ខ. អត់ដែរ ។

ក. ហើយសម្រាប់ជីដូនជីតាបងហ្នឹង គឺគាត់ពីមុននៅស្រុកចិន ។

ខ. គាត់នៅស្រុកចិន ។

ក. ហើយហេតុអីគាត់បានមកស្រុកខ្មែរ ?

ខ. មកជំនាន់ហ្នឹងដូចថា ចិនរកស៊ីស្រុកខ្មែរច្រើន អត់ដឹងថាម៉េចទេប៉ុន្តែមកជំនាន់នឹងចុះ ។ នៅជំនាន់ហ្នឹងចិនមកស៊ីស្រុកខ្មែរ ហើយក៏មកនៅស្រុកខ្មែរនឹងទៅបានមានប្រពន្ធមានកូនកើតកូនកើតចៅយើងទៅ ។

ក. បងបានកើតនៅ ១៩៧០ មែនអីបង ? អញ្ចឹងសម័យហ្នឹងវាទាន់សម័យប៉ុលពតដែរ មែនអីបង ?

ខ. ៧៥ ចូលប៉ុលពតពេញហ្មង។

ក. តើបងអាចសូមជួយប្រាប់ខ្ញុំខ្លះៗអំពីសម័យប៉ុលពតដែលបងឆ្លងកាត់មកទេ ?

ខ. សម័យប៉ុលពតហ្នឹងបងធ្លាប់ បងចាំតិចៗដែរ កាលហ្នឹងបងពិការ អញ្ចឹងគេអត់ឱ្យបងធ្វើអីទេ ។ គេឱ្យបងនៅផ្ទះ អញ្ចឹងលើពេលម៉ោងបាយអញ្ចឹងគេឱ្យបងហ្នឹងទៅបើកបាយនៅកន្លែងរោងបាយ បើកបាយញ៉ាំហើយមកផ្ទះវិញមក ។ ពេលល្ងាចឡើងទៅបើកបាយ ព្រលឹមឡើងទៅ បើកបាយនៅកន្លែងរោងបាយ ប៉ុលពត ។ កាលហ្នឹបងនៅតូចអាយុ៧ឬ៨ឆ្នាំប៉ុន្តែអាចចាំបានខ្លះៗ ។ ប៉ុន្តែបងគេអត់ឱ្យបងធ្វើអីបងពិការអញ្ចឹងនៅផ្ទះ ផ្ទះមួយហ្នឹងនៅចាំផ្ទះម្នាក់ឯង ម្ដាយឪពុកបងប្អូនទៅ អស់ ហើយដេកម្នាក់ឯងក្នុងផ្ទះមួយហ្នឹង ។

ក. យប់ឡើង ?

ខ. ហ្នឹងហើយ យប់ឡើង ថ្ងៃឡើងនៅម្នាក់ឯង ។ ម្ដាយឪពុកបងប្អូន គេទៅតាម ចល័ត តាមអីអស់អញ្ចឹងយើងនៅម្នាក់ឯងនៅចាំផ្ទះហ្នឹង ។ ហើយជំនាន់ប៉ុលពតលំបាកណាស់។ ពេលបងឈឺ បងឈឺហ្នឹងអញ្ចឹងម្ដាយបងយកមកមើលថែ អញ្ចឹងអង្គការគេថា គេអត់ឱ្យយកមកទេ នាក់ឯងមិនមែនពេទ្យទេ ទុកឱ្យខ្ញុំយកកូនហ្នឹងទៅពេទ្យដោយអញ្ចឹងម្ដាយខ្ញុំអត់ឱ្យគេយកខ្ញុំទៅទេ ថាបើគេយកទៅគេមានតែសម្លាប់ចោល អញ្ចឹងគាត់អត់ឱ្យគេយកខ្ញុំទៅទេ ហើយខ្ញុំតូចចិត្តដោយសារអញ្ចឹង៖ បើម៉ាក់ឯងឱ្យខ្ញុំទៅគេ ហើយគេយកទៅសំម្លាប់ចោលឬក៏ទៅព្យាបាលឱ្យជាជម្ងឺ ខ្ញុំប្រហែលជាមានសំណាងជាងរាល់ថ្ងៃ ដូចថាបើបានគេយកទៅសម្លាប់ចោលទៅ ដូចថាយកមានថាប់កើតមួយទៀតបានល្អដូចគេដូចឯងយើងនឹកឃើញថាយើងពិការអញ្ចឹងពិបាក នឹងជំនាន់ប៉ុលពត ហើយថាគេបើកបាយឱ្យញ៉ាំ គេរាល់ក្នុងមួយពេលគេឱ្យយើងពីរវែក តែបបរហ្នឹង មាន តែទឹកហើយនិងគ្រាប់ពោតទេអត់មានគ្រាប់អង្ករទេ គ្រាប់អង្ករមួយគ្រាប់មួយគ្រាប់ ។ សឹងតែអត់មាន ជំនាន់ប៉ុលពត ។

ក. ហើយមានអីឆ្លងកាត់ទៀតបង ?

ខ. បង ដូចថាម្ដាយអញ្ចឹងឱ្យនៅផ្ទះម្នាក់ឯង ពេលបងឈឺគាត់យកបងទៅកង ចល័តជាមួយគាត់ហើយ យកទៅកងចល័តយគាត់អញ្ចឹងពេលគេបើកអីឱ្យញ៉ាំអត់បានញ៉ាំទេពីព្រោះយើងឈឺ ។

ក. គេមានវាយដំអីបង ពេលនឹង ?

ខ. អត់ទេ ។ ពេលហ្នឹងងបងនៅតូចដល់ពេលអញ្ចឹងយើងឈឺទៀតគេអត់មាននេះទេ ។ គ្រាន់ថាម្ដាយឪពុកយើងហ្នឹងគេមិនវាយដំធ្វើបាបទេ គ្រាន់តែគេបង្ខំឱ្យយើងធ្វើការអញ្ចឹង បែកកូនបែកក្រុមគ្រួសាររស់នៅរៀងៗខ្លួន អត់អាចជួបជុំគ្រួសាទេ ។

ក. បងថាឪពុកបងបានស្លាប់នៅក្នុងសម័យប៉ុលពតហ្នឹងមែនទេបង?

ខ. ចា៎!

ក. អញ្ចឹងហេតុអ្វីបានគេសម្លាប់គាត់សម័យហ្នឹងបង ?

ខ. សម័យហ្នឹងនិយាយទៅជំនាន់ ៧៣ ហ្នឹងវាអត់ទាន់ចូលប៉ុលពតខ្លាំងទេ វានៅដំបូងជំនាន់៧៣ ហ្នឹង គេឃើញគាត់ហ្នឹងគាត់ចេះដូចថាគាត់ចេះលក់ដូរ កាលហ្នឹងជំនាន់ហ្នឹងគាត់ទៅទិញឥវ៉ាន់នៅផ្សារយើងមកលក់នៅផ្ទះនៅអី ដែលអញ្ចឹងអ្នកជិតខាងគេហ្នឹងគេឃើញ យើងអញ្ចឹងហើយគេច្រណែនគេថាយើងលក់ដូរលក់អីគេរាយការណ៍ រាយការណ៍ទេគេចាប់គាត់យកទៅ គាត់មកពីផ្សារវិញអត់ទាន់ញ៉ាំបាយទេ អត់ទាន់ញ៉ាំបាយគេមកបណ្តើរ គាត់យកទៅ ប្រាប់ថាគាត់យកទៅរៀន ហើយអញ្ចឹងម៉ាក់ខ្ញុំគាត់ថាបើលោកយកគាត់ទៅរៀនសូមយកខ្ញុំទៅទៅ ពីព្រោះគាត់មកអត់ទាន់ញ៉ាំបាយអត់ទាន់អីអញ្ចឹង សូមឱ្យគាត់នៅញ៉ាំបាយនៅអីសិន គេថាអត់ទេ គេហៅពីណាគេយកពីហ្នឹងទៅ ។ អញ្ចឹងគ្រាន់តែយកទៅបណ្តើរចេញផុតទៅពីមុខយើងគេចង ចង ស្លាបសេកគាត់។ បាត់ តាំងពីពេលហ្នឹងរហូត ប៉ុន្តែឮតែគេថាចេញទៅហ្នឹង បានតែមួយថ្ងៃពីរថ្ងៃគេ សំម្លាប់ចោល។ យើងអត់អាចតាមដានដូចស្រុកសម័យយើងឥឡូវទេ ។

ក. ដោយសារកាលហ្នឹងគាត់ជាអ្នកអីគេបង? អ្នករៀនសូត្របង ?

ខ. និយាយទៅគាត់អ្នកជួញដូរ ។

ក. គាត់ជាអ្នកជួញដូរពេលសម្លាប់ដែរ ?

ខ. ហ្នឹងហើយ និយាយរួមឱ្យទៅអ្នកជួញដូរ អ្នកចេះដឹងក៏ពួកវាអត់ទុកទេ ។

ក. ឪពុកបងពីមុនប៉ុលពតនឹងគាត់ធ្វើការអីខ្លះបង?

ខ. គាត់អត់ធ្វើអី គាត់ធ្វើសម្លការ ។ កាលពេលមុនប៉ុលពតគាត់ធ្វើសម្លការ គាត់កាប់ជ្រូកកាប់អីអញ្ចឹង ដល់ពេលមកចូលមកមិនទាន់ចូលប៉ុលពតទេនៅ ៧៣ គ្រាន់ថាវាជិតចូល ដល់៧៥ចូលពេញហ្មង។ ពេល៧៣គាត់នៅរកស៊ីអញ្ចឹងប៉ុន្តែគេចាប់គាត់តាំងពី៧៣ ។

ក. អញ្ចឹងម្តាយបងធ្វើការអីគេដែរពេលហ្នឹង?

ខ. ពេលហ្នឹងម្តាយបងនៅតែនៅផ្ទះមើលកូន ។

ក. ហើយនៅសម័យប៉ុលពតម្តាយបងធ្វើអ្វីខ្លះបង ?

ខ. សម័យប៉ុលពតបែកពីកូនចៅទៅ គាត់ទៅរស់នៅតាមកងចល័តអញ្ចឹងគេឱ្យគាត់លើកដី ស្ទូងដក អត់មានធ្វើអីក្រៅពីអញ្ចឹង ។

ក. ហើយកូនៗទាំងអស់ហ្នឹងនៅជាមួយឪពុកម្តាយដែរ? ឬក៏...?

ខ. អត់មានទេ បែកអស់ បែកគ្នា ។ ចូលប៉ុលពតមកអញ្ចឹងបងនៅចាំផ្ទះយើងទៅហើយម្តាយនៅផ្សេង បងប្អូនប្រុសស្រីនៅផ្សេងបែកទាំងអស់ ។

ក. បងដឹងទេថាហេតុអីគេបានដាក់គ្រួសាហើយបងប្អូនបែកពីគ្នាអញ្ចឹងបង ?

ខ. មិនដឹងដែរប៉ុន្តែជាទូទៅគឺក្រុមគ្រួសាទាំងអស់គឺអញ្ចឹង គឺអញ្ចឹងទាំងអស់អត់មានឱ្យនៅជុំគ្នាទេ។ កូនធ្វើនៅផ្សេងៗឆ្ងាយៗ ពីគ្នាអត់អាចឃើញគ្នាអត់អាចដឹងឮអីទាំងអស់ ។

ក. ហើយដល់ពេលអញ្ចឹង នៅពេលដែលបែកពីប៉ុលពត់នឹងមក ធ្វើម៉េចបានកូនចៅជុំគ្នាវិញបានទេ ?

ខ. បែកពីប៉ុលពតអញ្ចឹងទៅ កាលពេលហ្នឹងម្តាយបងម៉ោងប្រាំហ្នឹង ម៉ោងប្រាំ ម៉ោងប្រាំមួយហ្នឹង គេត្រូវយកគាត់ទៅសំលាប់ចោល ដល់ពេលម៉ោងប្រាំម៉ោងប្រាំមួយហ្នឹងវៀតណាមចូល ។ វៀតណាមចូល<<យើងបើករថក្រោះផ្លូវយើងទាំងអស់ដល់អញ្ចឹងទៅគេហៅបែកប៉ុលពត ដល់អញ្ចឹងទៅកូនចៅរត់រកម្តាយ បងប្រុសខ្ញុំពីរនាក់គេហៅគេយកទ្បានមកយកហៅអីហៅទៀត យកទៅស្រុកគេ គាត់ថាគាត់អត់ទៅអីព្រោះគាត់បែកម្តាយគាត់តាំងពីក្មេងៗ ដល់អញ្ចឹងគាត់រត់រកម្តាយឪពុក ។

ក. ដល់ពេលអញ្ចឹងបានជុំគ្នាវិញទៅ ។ ហើយដល់ពេលបងជួបគ្នាហើយបងនៅទីកន្លែងដែលមុនដំបូងមុនអស់នៅម៉្ដុំណាវិញបង?

ខ. បងនៅភូមិរស្មី ។

ក. រស្មីនៅណាវិញបង?

ខ. ភូមិរស្មីនឹងនៅខេត្តកំពង់ធំ ។

ក. ហើយនៅពេលដែលបងចូលសម័យប៉ុលពតហ្នឹងបងនៅខេត្តណា ?

ខ. បងនៅហ្នឹងដែរ ។ ហើយផ្ទះដែលបងដែលបងនៅណាប៉ុលពតធ្វើឱ្យ ។ នៅក្នុងភូមិមួយៗ ប៉ុលពតធ្វើផ្ទះឱ្យ ៥ម៉ែត បណ្ដោយ ៧ កាំជណ្តើរតែប្រាំទេ លើសពីប្រាំគឺអត់អោយទេសូម្បីតែមួយតឹកពីរតឹកក៏មិនអោយ គេកំណត់ឱ្យកាំជណ្តើរតែប្រាំទេ សម្រាប់ដូចថាយប់អីយើង គេដើរស៊ើបតាមក្រោមផ្ទះក្រោមអីចឹង ឱ្យឮ បើសិនជាធ្វើខ្ពស់គេអត់នេះទេ ។ គេអត់ឱ្យធ្វើខ្ពស់ឱ្យធ្វើទាបៗ ។

ក. អញ្ចឹងនៅពេលដេលបងបានចេញពីសម័យប៉ុលពតនឹងមកបងនៅតែនៅកំពង់ធំហ្នឹងទេ?

ខ. បងនៅហ្នឹងអត់ទៅណាទេ ។

ក. ហើយដល់ពេលបងនៅហ្នឹងក្រុមគ្រួសាទាំងអស់គឺហ្នឹងទាំងអស់គ្នា ។

ខ. នៅហ្នឹង ចំា!

ក. ហើយនៅពេលហ្នឹងបងប្រកបអាជីវកម្មអីគេដែរពេលហ្នឹង ?

ខ. លក់ដូរធម្មតា ។ ធ្វើស្រែធ្វើចម្ការអញ្ចឹងលក់ដូរធម្មតា ។

ក. អញ្ចឹងការរៀនសូត្របងវិញ បងរៀនពីមុនប៉ុលពតហ្នឹងបងបានរៀនអី ?

ខ. ពីមុនបងអត់បានរៀនទេ ។

ក. ដល់ពេលចប់ប៉ុលពតមក ?

ខ. ចប់ប៉ុលពតមកបានចាប់មានសាលារៀន ។ ដែលអញ្ចឹងបងចូលរៀនពីថ្នាក់ទីមួយ ដល់ថ្នាក់ទីប្រាំអត់មានលទ្ធភាពទៅទៀត ។ ដោយសារបងជីវភាពគ្រួសាបងវាទីទាល់ក្រដល់ពេលអញ្ចឹង បងអត់ចេះជិះកង់ ដល់ទៅរៀនសាលាឆ្ងាយ ដោយអញ្ចឹងបងអត់អាចមានលទ្ធភាព តទៅទៀតបងឈប់ត្រឹមថ្នាក់ទីប្រាំ ។

ក. សាលាបងឈ្មោះអីគេដែរ ?

ខ. សាលារៀន តាំងគោក។

ក. នៅណាវិញបង?

ខ. នៅជិតផ្ទះដែរ ។

ក. នៅកំពង់ធំហ្នឹងបង ?

ខ. នៅខេត្តកំពង់ធំ ។

ក. ហើយកាលពីមុនបងធ្វើស្រែចម្ការហ្នឹង តើបងចេះធ្វើអ្វីបន្ថែម ពីហ្នឹងបង?

ខ. លក់ដូរធម្មតា ។

ក. បងលក់អីគេវិញ?

ខ. លក់ដូរដូចជាបន្លែដូចជានំបញ្ចុកដូចជាអីយើង យើងរកចេះតែចល័តរកគ្រប់មក។

ក. អញ្ចឹងសម្រាប់ជីវិតឥឡូវហ្នឹងវិញបង បងគិតថាជីវិតឥឡូវហ្នឹងយ៉ាងម៉េចដែរបង ?

ខ. ជីវិតឥឡូវវាខុសពីមុន ដោយសារឥឡូវបងអត់លក់ដូរទេ ។ បងធ្វើការអញ្ចឹងទៅ បងធ្វើការបងអាចដើរក្រៅ ដើរធ្វើក្រុចកធ្វើអី ថ្ងៃសៅរ៍អាទិត្យឡើងបងដើរធ្វើក្រចក ។ ហើយថ្ងៃធម្មតាពីច័ន្ទដល់សុក្រអញ្ចឹងបងធ្វើការងារ ។

ក. ហើយបងគិតថាជីវិតរបស់បងពីមុនឥឡូវវាខុសប្លែកគ្នាបង ?

ខ. ខុសប្លែកពីមុន។

ក. គិតថាវាល្អជាងមុនឬក៏វាអាក្រក់ជាងមុន ?

ខ. វាល្អជាងមុន ។

ក. ដោយសារអ្វីជាល្អជាងមុនបង ?

ខ. ដោយសារដូចថាស្រុកទេសយើងប្រែប្រួល ឥឡូវហ្នឹងយើងមានមុខរបរច្រើន មានជំនាញច្រើន។

ក. អរគុណច្រើនបងសម្រាប់ការសម្ភាសដែលបងបានប្រាប់ច្រើន ប៉ុន្តែខ្ញុំចង់សួរបន្ថែមមួយទៀតថា បងដែលមានបញ្ហាអ្វីដែលបងគិតថាពិបាកខ្លាងបំផុតនៅក្នុងឆាកជីវិតរបស់បង ?

ខ. នៅក្នុងឆាកជីវិតរបស់បង បងពិបាកបំផុត បងអត់ដែលចេញពីផ្ទះ បងនៅជាមួយម្ដាយរហូតរហូតដល់ថ្ងៃមួយ បងលក់ឥវ៉ាន់នៅផ្ទះហ្នឹង លក់ៗអស់ដើមអស់ចុង ដោយសារបងឈឺបងហ្នឹងមានកូនប្រុសឈឺមួយទៀត ដល់ពេលអញ្ចឹងបងត្រូវរ៉ាប់រងក្នុងគ្រួសារដែរ អញ្ចឹងទៅបងហ្នឹងអស់ដើមអស់ចុងអាលឹងបងនឹងដើរចេញពីផ្ទះមករកការងារធ្វើថាប់ពី២០០១ នឹងមកបងចេញពីផ្ទះមករហូត បែកម្ដាយបែកបងបែកប្អូនមកអញ្ចឹង ។

ក.  សម្រាប់ភាពល្អវិញបងគិតថាក្នុងឆាកជីវិតបងដែលជួបនៅភាពល្អបំផុតទេបង ?

ខ.  ឥឡូវអត់ទាន់មានទេ ព្រោះទាំងពីដឹងក្តីមកប៉ុននេះមកជួបរឿងលំបាករហូតសូម្បីតែមានគ្រួសារមានកូនគឺតែនៅតែមានភាពលំបាកដែរ ។

ក.  អញ្ជឹងអរគុណច្រើនបងសម្រាប់ជីវប្រវត្តិដែលបងបានប្រាប់ វាពីតជាកម្សត់មែន សម្រាប់ជីវិតយើងម្នាក់ៗ ថាគ្មាននរណាម្នាក់នៅល្អទេមានបទពិសោធពិបាក សប្បាយរីករាយ ទុក្ខព្រួយ អ្វីទាំងអស់ហ្នឹង ប៉ុន្តែអ្វីទាំងអស់ហ្នឹងគឺជាមេរៀនមួយសម្រាប់យើងទាំងអស់គ្នា ហើយសូមថ្លែងអំណរគុណខ្លាំងមែនទែនសម្រាប់ការសម្ភាសនេះហើយខ្ញុំដឹងថាមួយនេះគឺជាពរជ័យមួយសំរាប់កូនចៅបងសម្រាប់ប្រជាពលរដ្ឋខ្មែរយើងជំនាន់ក្រោយដែលគាត់បានស្តាប់ហើយគាត់បានសិក្សាអំពីជីវប្រវត្តិរបស់បងរបស់អ្វីទាំងអស់ ហ្នឹងហើយ ហើយអញ្ជឹងនៅពេលដែលខ្ញុំចប់ខ្ញុំសូមថតរូបបងហើយបន្ទាប់មកទៅខ្ញុំនឹងសម្លេងរបស់បងនឹងដាក់ចូលឌីស្កនេះ ហើយជូន ឌីស្កនេះបងមួយដែរហើយបងអាចទុកស្តាប់នៅថ្ងៃក្រោយផងដែរ បាទហើយអញ្ជឹងថ្ងៃហ្នឹងមានតែប៉ុណ្ណឹង អរគុណច្រើន។ តើបងមានអ្វីចង់បន្ថែមទៀតទេ ? ចង់ឱ្យកូនចៅបងស្តាប់ថ្ងៃក្រោយទៅ ៗ

ក.  ថាបើកូនចៅបងប្អូនបានឮរឿងដែលខ្ញុំនិយាយអញ្ជឹងដល់ហើយកូននឹងដឹងថាខ្ញុំកម្សត់ ។

ខ.  បាទបងអរគុណច្រើន ។